ឧបសម្ព័ន្ធ ១

# របាយការណ៍បូកសរុប
# ប្រចាំឆ្នាំ២០១៩



# អង្គការកែប្រែសហគមន៍

ប្រភពមូលនិធិ:

មាតិការ

I. អំពីអង្គការកែប្រែសហាគមន៍
II. ពត៌មានគម្រោង
III. ពិពណ៌នាការរីកចម្រើនរបស់គម្រោង (ឧបសគ្គរាំងស្ទះនិងមេរៀន)
IV. របាយការណ៍ហិរញ្ញវត្ថុ
V. ផែនការទិសដៅការងារបន្ត

## I. អំពីអង្គការកែប្រែសហគមន៍

អង្គការកែប្រែសហគមន៍ Community Translation Organization, អក្សរកាត់ (CTO) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលត្រូវបានចុះបញ្ជីរនៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា លេខ ១៩៩៣ សជណ ថ្ងៃទី៣០ ខែមិនថុនា ឆ្នាំ ២០០៩។ ស្នាក់ការកណ្តាលរបស់អង្គការមានទីតាំងស្ថិតនៅ ផ្ទះលេខ ០៩៩ ផ្លូវជាតិលេខ៦ ភូមិថ្មល់ សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប។ ដែលជាទីតាំងយុទ្ធសាស្រ្តមួយដើម្បី សម្របសម្រួលប្រតិបត្តិការណ៍ការងារចូលរួមកិច្ចការអភិវឌ្ឍន៍ សម្រាប់បណ្តាខេត្តភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជាដូចជាខេត្ត សៀមរាប ព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង និងកំពង់ធំ។

អង្គការកែប្រែសហគមន៍ ធ្វើការងារដើម្បីកសាងមូលដ្ឋានគ្រឹះ សម្រាប់សហគមន៍ដែលអាស្រ័យផលនឹងរបរកសិកម្ម ដោយផ្តោតលើការងារកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ ការកសាងសមត្ថភាពក្រុមអង្គការកសិករ ដែលមានដូចជាក្រុមសន្សំប្រាក់ សហគមន៍កសិកម្ម សហគមន៍ព្រៃឈើ សហគមន៍ទេសចរធម្មជាតិ សហគមន៍ស្រះជម្រកត្រីមេពូជ ជម្រុញការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ការអប់រំផ្សព្វផ្សាយដល់សហគមន៍លើបញ្ហាបម្រែបម្រួល អាកាសធាតុ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយគ្រោះភ័យធម្មជាតិ ដើម្បីឆ្ពោះទៅរកការកសាង សមត្ថភាពសហគមន៍ ដែលអាចធន់ទ្រាំទៅនឹងបញ្ហាសង្គម និងសេដ្ឋកិច្ច។

អង្គការកែប្រែសហគមន៍ គឺជាផ្នែកមួយនៃកម្មវិធីរបស់អង្គការ Human Translation ដែលជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយ មានមូលដ្ឋាននៅសហរដ្ឋអាមេរិក (គេហទំព័រwww.humantranslation.org)។ ក្នុងឆ្នាំ២០០៩ តាមរយៈការធ្វើកំនែទម្រង់អង្គការកែប្រែសហគមន៍ បានប្រែក្លាយមកជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យក្នុងស្រុកមួយ ដែលបានចុះបញ្ជីទទួលស្គាល់ស្របច្បាប់ជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅក្រសួងមហាផ្ទៃ។

- <u>បាវចនា</u> ៖ ប្រែក្លាយចំណេះដឹងទៅជាសកម្មភាពអភិវឌ្ឍន៍
- <u>ទស្សនវិស័យ</u> ៖ កសិករអាចធ្វើកិច្ចការដើម្បីកែលំអរជីវភាព និងសេដ្ឋកិច្ចបានប្រសើរឡើង នៅពេលដែលពួកគាត់ទទួលបាននូវសម្ភារៈ ចំណេះដឹង ជំនាញ និងធនធានសមស្រប
- <u>បេសកកម្ម</u> ៖ ចូលរួមជាមួយសហគមន៍ ដើម្បីការត់បន្ថយភាពក្រីក្រ អភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការគាំទ្រ ហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ អេកូទេសចរណ៍ និងធ្វើអោយប្រសើរឡើងនូវការ ចិញ្ចឹមជីវិតដោយភាពថ្លៃថ្នូរ និងមានការការគោរពសិទ្ធិសេរីភាពពេញលេញ។

## ក្រុមប្រឹក្សាភិបាលរបស់អង្គការ

| ឈ្មោះ | ឋានៈ និង ស្ថាប័ន | អាស័យដ្ឋាន |
|---|---|---|
| Tobias Rose-Stockwell | ស្ថាបនិក<br>ប្រធានក្រុមប្រឹក្សាភិបាល | California, USA<br>E-mail: tobias@humantranslaionn.org |
| Jon Morgan | សមាជិកក្រុមប្រឹក្សាភិបាល<br>/ប្រធាន LAKECLINIC.org | សាលាកំរើក ក្រុងសៀមរាប<br>E-mail: jmorgan@lakeclinic.org |
| Kat Bun Heng | ស្ថាបនិក<br>សមាជិកក្រុមប្រឹក្សាភិបាល | សាលាកំរើក ក្រុងសៀមរាប<br>E-mail: kat.bunheng@gmail.com |
| Kristen Davies | សមាជិកក្រុមប្រឹក្សាភិបាល | សាលាកំរើក ក្រុងសៀមរាប |

| | ទីប្រឹក្សា GIZ ប្រចាំសៀមរាប | E-mail : kdavies025@gmail.com |
|---|---|---|

## បុគ្គលិកលេខាធិការដ្ឋាន

| ល.រ | នាម និងគោត្តនាម | ឋាន: និង ស្ថាប័ន | អាស័យដ្ឋាន | ទំនាក់ទំនង |
|---|---|---|---|---|
| ១ | លោក យិញ យ៉ា | នាយកប្រត្តិបត្តិ(ពេញម៉ោង) | សៀមរាប | ០១២៧០៧៤៧៤ |
| ២ | លោកស្រី សៀង សុធារី | ប្រធានគ្រប់គ្រងហិរញ្ញវត្ថុ(ពេញម៉ោង) | សៀមរាប | ០១២៤៥១៨៧៧ |
| ៣ | លោក ថៃ ពិសី | ប្រធានកម្មវិធី(ពេញម៉ោង) | សៀមរាប | ០៩២៦២២១៨១ |
| ៤ | លោក ម៉យ រ៉ាមន | មន្ត្រីកម្មវិធី(ពេញម៉ោង) | សៀមរាប | ០៩២៧២៨១៩២ |
| ៥ | លោក សួន វាសនា | មន្ត្រីកម្មវិធី(ពេញម៉ោង) | សៀមរាប | ០៩២៥៥៣០១៣ |
| ៦ | លោក រិត ប្ញូ | ប្រធានសម្របសម្រួលខេត្ត(ពេញម៉ោង) | ឧត្តមានជ័យ | ០១២៣៥១៦៩៦ |
| ៧ | លោកស្រី ទេព សាម៉េត | មន្ត្រីកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៩២៥០២៦២០ |
| ៨ | កញ្ញា ខា គឹមយួយ | មន្ត្រីជំនួយការកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៩៣២៤០១០១០ |
| ៩ | លោកស្រី យ៉ាន់ ម៉ូរជី | មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ(ពេញម៉ោង) | ឧត្តមានជ័យ | ០១២៣១៧៩៩៧ |
| ១០ | កញ្ញា សួន សោភា | មន្ត្រីកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៨៨៩៩១៨០៥០ |
| ១១ | កញ្ញា ទីវ សារ៉ន្ត | ជំនួយការរដ្ឋបាល(ពេញម៉ោង) | សៀមរាប | ០៩៩៧០១៣៧៣ |
| ១២ | Ms. Elise Fanene | អ្នកស្ម័គ្រចិត្ត | បារាំង | elise.fanene@sfr.fr |
| ១៣ | Ms. Garance Mandon | អ្នកស្ម័គ្រចិត្ត | បារាំង | garancemandon@gmail.com |
| ១៤ | Ms. Camille Peiffer | អ្នកស្ម័គ្រចិត្ត | បារាំង | camille.peiffer@orange.fr |
| ១៥ | Ms.Camille Supplison | អ្នកស្ម័គ្រចិត្ត | បារាំង | camillesup@hotmail.fr |

## វិស័យផ្តោតការយកចិត្តទុកដាក់

| ប្រភេទនៃកម្មវិធី សកម្មភាព/គម្រោង/ | ទីកន្លែង | រយ:ពេល | ដៃគូគម្រោង | ប្រភពថវិកា / យន្ទំជ | ស្ថានភាព/បញ្ចប់/កំពង់បន្ត |
|---|---|---|---|---|---|
| សន្តិសុខស្បៀង ពង្រឹងសិទ្ធមូលដ្ឋាន អភិបាលកិច្ច អប់រំនិងយែនឌ័រ | សៀមរាប | ៣ឆ្នាំ | -ក្រុមប្រឹក្សឃុំ<br>-<br>ការិយាល័យអប់រំស្រុក | Actionaid | បញ្ចប់ ០១មេសា២០១៦ |
| និយ័តកម្មព្រៃឈើ ទឹកស្អាតនិងអនាម័យ | ព្រះវិហារ | ៣ ឆ្នាំ | -សហគមន៍ព្រៃឈើ<br>-រដ្ឋបាលព្រៃឈើ<br>-មន្ទីរអភិវឌ្ឍន៍ជនបទ | OXFAM GB | បញ្ចប់ ០៨សីហា២០១៥ |
| អេកូទេសចរណ៍ គ្រប់គ្រងធនធានធម្មជាតិបំរែបំរួលអាកាស ធាតុការចិញ្ចឹមជីវិត | សៀមរាប | ២ ឆ្នាំ | ក្រុមប្រឹក្សឃុំ | UNDP SGP | បញ្ចប់ ៣០ធ្នូ២០១៣ |
| សេដ្ឋកិច្ចកសិកម្ម និងទីផ្សារ | សៀមរាប | ៧ឆ្នាំ | សហគមអភិវឌ្ឍកសិកម្ម | SIDA/ WEFFECT | បន្ត |
| សេដ្ឋកិច្ចកសិកម្ម និងទីផ្សារ | សៀមរាប | ៥ ឆ្នាំ | មន្ទីរកសិកម្ម | AusAID | បញ្ចប់ ០៦កក្កដា២០១៤ |
| សន្តិសុខស្បៀង ពង្រឹងសិទ្ធមូលដ្ឋាន | ឧត្តរមានជ័យ | ៧ឆ្នាំ | -បណ្តាញសហគន៍ព្រៃឈើ | Actionaid | បន្ត |

| | | | | | |
|---|---|---|---|---|---|
| អភិបាលកិច្ច អប់រំ និងយែនឌ័រ គ្រប់គ្រង់គ្រោះមហន្តរាយ | | | -បណ្ដាញគាំទ្រសហគមន៍ | | |
| គ្រប់គ្រងធនធានធម្មជាតិបំរែបំរួលអាកាសធាតុការចិញ្ចឹមជីវិត | សៀមរាប | ១.៨ ឆ្នាំ | ក្រុមប្រឹក្សឃុំ ឧទ្យានជាតិ រដ្ឋបាលស្រុក | UNDP SGP | បញ្ចប់ ២០១៨ |
| កសិកម្ម និងការចិញ្ចឹមជីវិត | សៀមរាប | ១ឆ្នាំ | សហគមន៍កសិកម្ម | DAP/DIFAT | បញ្ចប់ ២០១៨ |
| ជម្រុញសហគ្រិនវ័យក្មេង | សៀមរាប | ១ឆ្នាំ | ពាណិជ្ជកម្ម | PACT/WE Act | បន្ត |

## II. ពត៌មានគម្រោង

១.ខេត្តសៀមរាប មាន២គម្រោងដែលប្រភពថវិកាមកពីម្ចាស់ជំនួយ WeEffect, PACT/USAID

គម្រោងទី១

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងបង្កើនសមត្ថភាពផ្នែកសង្គម និងសេដ្ឋកិច្ច របស់អង្គការកសិករ ដោយមានការចូលរួមដ៏មានអត្ថន័យពីស្ត្រី នៅខេត្តសៀមរាប ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ |
| គោលដៅរួម | ចូលរួមកាត់បន្ថយភាពក្រីក្រប្រជាពលរដ្ឋតាមរយៈការពង្រឹងសេដ្ឋកិច្ចកសិករនិងសមត្ថភាពអង្គការសហគមន៍ |
| តំបន់គោលដៅ | -ខេត្ត: សៀមរាប<br>-ស្រុក: ពួក ស្រុកបន្ទាយស្រី ស្រុកប្រាសាទបាគង ស្រុកសូត្រនិគមន៍<br>-ឃុំ: កែវពណ៌ សំរោងយា ពួក ត្បែង ខ្នាស់ ត្រពាំងធំ |
| ក្រុមគោលដៅ | សហគមន៍កសិកម្ម ១២ ក្រុមសន្សំ២៥ក្រុម សហភាពសហគមន៍កសិកម្ម១ ក្រុមយុវជន៣ក្រុម |
| អ្នកទទួលផលផ្ទាល់ | ១៤៨៦គ្រួសារ |
| អ្នកទទួលផលប្រយោល | ៣០០០នាក់ ស្ត្រី ១៥៨៨នាក់ |

គម្រោងទី២

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងជម្រុញសហគ្រិនស្ត្រីវ័យក្មេង(WE Act) |
| គោលដៅរួម | សម្របសម្រួល ជម្រុញក្រុមស្ត្រីវ័យក្មេងឲ្យទទួលបានវគ្គបណ្តុះបណ្តាលតាមជំនាញដែលពួកគេត្រូវការ និងកំពុងអនុវត្តដើម្បីមានចំណេះ ជំនាញពិតប្រាកដ |
| តំបន់គោលដៅ | -ខេត្ត: សៀមរាប<br>-ក្រុង សៀមរាប |
| ក្រុមគោលដៅ | (១)-អាជីវករជាស្ត្រីដែលមានមុខរបរស្រាប់ និងកំពុងរៀបចំបើកអាជីវកម្មផ្ទាល់ខ្លួនចំនួន២៥០នាក់ |
| អ្នកទទួលផលផ្ទាល់ | ២៥០គ្រួសារ |
| អ្នកទទួលផលប្រយោល | ១៥៧៥នាក់ ស្រី៨៥៥នាក់ |

២.ខេត្តឧត្តរមានជ័យ មានគម្រោងមេ១ដែលប្រភពថវិកាមកពី Actionaid

| | |
|---|---|
| ឈ្មោះគម្រោង | កម្មវិធីសិទ្ធិមូលដ្ឋាន (LRP) |
| គោលដៅរួម | កសិករ និងកុមារក្រីក្រនៅក្នុងតំបន់គោលដៅរបស់គម្រោង នឹងទទួលបាននូវសន្តិសុខស្បៀង និងឱកាសទទួលបានការសិក្សាប្រសើរជាងមុន ដោយពួកគេមានលទ្ធភាព ទទួលបាននូវសិទ្ធិជាមូលដ្ឋាន ហើយអនុវត្តសិទ្ធិទាំងនោះតាមផ្លូវច្បាប់ ដើម្បីរស់នៅប្រកបដោយភាពថ្លៃថ្នូរនៅក្នុងសង្គម។ |
| តំបន់គោលដៅ | -ខេត្ត: ឧត្តរមានជ័យ<br>-ស្រុក: សំរោង បន្ទាយអំពិល ចុងកាល់ អន្លង់វែង<br>-ឃុំ: សំរោង បន្សាយរាក់ កូនក្រៀល គោកខ្ពស់ ពង្រ លំទង |

| | |
|---|---|
| ក្រុមគោលដៅ | សហគមន៍ព្រៃឈើ ៤ ក្រុមសន្សំ៨ក្រុម បណ្តាញសហគមន៍ព្រៃឈើខេត្ត១ ក្រុមជង្រុកស្រូវ ៨ សាលាបឋមសិក្សា២០ |
| អ្នកទទួលផលផ្ទាល់ | ១៨៦៣គ្រួសារ |
| អ្នកទទួលផលប្រយោល | ៩៣៣៨នាក់ ស្រី៤៧៥០នាក់ ក្នុងនោះកុមារសរុប៣២៦៨នាក់ |

**ពិពណ៌នាការរីកចម្រើនរបស់គម្រោង**

**១.ខេត្តសៀមរាប**

*គម្រោងទី១*

**វិភាគលទ្ធផល**

ក្នុងកំឡុងឆ្នាំ២០១៩នេះ អង្គការកែប្រែសហគមន៍ សម្រេចបានលទ្ធផលសំខាន់ៗ យោងទៅលើគោលបំណង ដែលបានព្រមព្រៀងក្នុងផែនការគម្រោង។ ផ្អែកទៅលើកត្តាភូមិសាស្ត្រ និងប្រជាសាស្ត្រ អង្គការកែប្រែសហគមន៍ធ្វើការនៅតាមបណ្តាខេត្តចំនួន៣គឺខេត្តសៀមរាប ព្រះវិហារ និងឧត្តរមានជ័យ។ ធ្វើការជាមួយសហគមន៍កសិកម្មចំនួន២២ សហភាពសហគមន៍កសិកម្ម១ ដែលមានសមាជិកសរុប២១៥៩នាក់ ដែល៦០%ជាស្ត្រី ដែលឋិតក្នុងឃុំ ២១ ស្រុក៨ នៃខេត្តទាំង៣ខាងលើ។ តាមការសង្កេតជារួម ការអនុវត្តសកម្មភាពគម្រោងបានសម្រេចទៅតាមលំដាប់លំដោយនៃផែនការ ដោយគ្មានការផ្លាស់ប្តូរអ្វីជាដុំកំភួនឡើយ នៅក្នុងកម្រិតគោលដៅ លទ្ធផលរយះពេលវែង និងខ្លី។ យ៉ាងណាក៏ដោយ ក៏មានការបត់បែនផ្លាស់ប្តូរតិចតួចទៅលើសកម្មភាពមួយចំនួន ប៉ុន្តែអង្គការកែប្រែសហគមន៍តែងតែឆ្លងការឯកភាពអនុម័តពី វីអេហ្វិកជាមុនសម្រាប់ការស្នើរះរើផ្លាស់ប្តូរសកម្មភាពទាំងនេះ ក្នុងកំឡុងពេលនៃការធ្វើការកែសម្រួលខ្ទង់ថវិកាប្រចាំឆ្នាំ។ លទ្ធផលកំឡុងឆ្នាំ២០១៩នេះរួមមាន ការបន្តជំនួញស្រូវអង្ករ របស់សហភាពសហគមន៍កសិកម្ម ដែលកំពុងដំណើរការជាជំហានចាប់តាំងពីខែតុលាឆ្នាំ២០១៨។ សហភាពសហគមន៍កសិកម្មសៀមរាបអង្គរ រួមគ្នាបង្កើតឡើងដោយសហគមន៍កសិកម្មចំនួន១០ក្នុងខេត្តសៀមរាប។ ដែលជំនួញចាប់ផ្តើមដំបូង ជាមួយនឹងដើមទុនចំនួន ១៨លានរៀល ដោយធ្វើការទិញវត្ថុធាតុដើមជាស្រូវពីសមាជិកចំនួន១៥តោនដើម្បីកិនវេចខ្ចប់ជាអង្ករសម្រប់លក់ចេញ។ម្យ៉ាងវិញទៀត សហភាពសហគមន៍កសិកម្មរំពឹងថានឹងផលិតជាអង្ករបានចំនួន ៦៧៥២ គក្រ។ តាមការព្យាករណ៍នូវប្រាក់ចំនួលពីជំនួញនេះក្នុងរយះពេល៥ខែគឺអាចនឹងរកបាន ១១៥ ៥៤៦ ៥០០ រៀល។ កសិកដ្ឋានគម្រូ៧ក្នុងចំនោម៩ កំពុងដំណើរល្អប្រសើរ ហើយបានដើរតួនាទីក្នុងការបង្ហាញជូននូវបច្ចេកទេសក្នុងការដាំដុះទៅដល់កសិករដែលរស់នៅជុំវិញ។ មានប្រជាកសិករទូទៅក្នុងភូមិបានមកមើល និងរៀនសូត្រដកស្រង់បទពិសោធន៍ដែល ៥០%នៃអ្នកដែលបានចូលរួមរៀនសូត្រនេះពួកគេបានយកទៅអនុវត្តបន្ត។ ក្រុមផលិតចំនួន ២០ក្រុមបានបង្កើតឡើងដែលភាគច្រើនសកម្មទៅលើក្រុមចិញ្ចឹមមាន់ ហើយនិងក្រុមដាំបន្លែ។ ជាពិសេសទៀតនោះ ក្រុមផលិតទាំងនេះនឹងធ្វើការផ្គត់ផ្គង់ផលិតផលកសិកម្មរបស់ពួកគាត់មកកាន់សហភាពសហគមន៍កសិកម្ម ហើយសហភាពសហគមន៍សិកម្មនឹងភ្ជាប់ផលិតផលទាំងនេះ ទៅកាន់ទីផ្សារក្នុងខេត្តសៀមរាបក៏ដូចជាខេត្តដទៃផ្សេងទៀតផងដែរ។ ការចូលរួមរបស់ស្ត្រីក្នុងគម្រោងមានបរិមាណច្រើនជាងបុរស។ តាមការសង្កេតឃើញថាស្ត្រីហាក់ដូចជាសកម្មក្នុងការចូលរួម ពួកគាត់មានភាពក្លាហានលើកនៅបញ្ហាកង្វល់នានារបស់ពួកគាត់ ហើយក៏ដូចជាការចែករម្លែកការគិតរបស់ពួកគាត់ ទៅកាន់សមាជិកផ្សេងទៀតរបស់សហគមន៍ជាពិសេសក្រុមបុរសៗ។ ប្រហែល៣០%=៦០នៃចំនួនសរុប១៧០នាក់ ក្នុងចំនោមជួរគណកម្មការដឹកនាំក្រុមសរុប៣៣៥នាក់ នៃសហគមន៍កសិកម្មទាំងអស់បានចូលរួមក្នុងដំណើរការកសាង និងសមាហរណកម្មផែនការឃុំ ដែលដំណើរការក្នុងកម្រិតថ្នាក់ឃុំ ហើយនឹងធ្វើការសន្ទនាជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ ពិសេសជាងនេះទៅទៀតនោះ មានស្ត្រី៥០%=១៧០នាក់ក្នុងចំណោមថ្នាក់ដឹកនាំគណកម្មការសហគមន៍ទាំងអស់ចំនួន៣៣៥នាក់ បានកាន់តួនាទីក្នុងជួរថ្នាក់ដឹកនាំនៅបណ្តាសហគមន៍កសិកម្មទាំង២២ សហភាពសហគមន៍កសិកម្ម១ ក្រុមសន្សំ ២៥ក្រុម ហើយនឹងក្រុមផលិតចំនួន២០ក្រុមនៅក្នុងបណ្តាខេត្តគោលដៅទាំង៣ មាន សៀមរាប ព្រះវិហារ ឧត្តរមានជ័យ។ ផ្អែកលើការវិភាគទៅលើកំណត់ត្រាប្រចាំខែ របស់កសិកដ្ឋានដំណាំគម្រូ និងចិញ្ចឹមសត្វចំនួន១៦ក្នុងគោលដៅគម្រោងក្នុងឆ្នាំ២០១៩ ប្រាក់ចំនូលប្រចាំឆ្នាំពីផលរបរកសិកម្ម របស់សហគមន៍គោលដៅមានការកើនឡើងរង្វង់ ៣៥% ដែលស្មើនឹងចំនួន ១ ៨៨២ ៥៣៣ រៀល ក្នុង១គ្រួសារ ក្នុង១ឆ្នាំ ចំនួននេះក៏រាប់បញ្ចូលទាំងប្រភពចំនូលដែលមិនមែនជាកសិកម្មតាមគ្រួសារផងដែរ។

| គោលដៅរួមគម្រោង | លទ្ធផលរំពឹងទុកសម្រេចឆ្នាំ២០១៩ |
|---|---|
| កសិករខ្នាតតូច ហើយនឹងក្រុមផលិតវិស័យកសិកម្មដែលស្ថិតក្នុងបន្ទាត់ក្រីក្រ ជាពិសេសស្ត្រី និង សហគមន៍ជនជាតិ | • កាត់បន្ថយ១៥% នៃកសិករគោលដៅគម្រោងដែលមានប្រាក់ចំនូលទាបជាងបន្ទាត់ក្រីក្រ នៅឆ្នាំ២០២២<br>• កើនឡើង២៥%នៃប្រជាជនសរុបក្នុងការចូលរួមធ្វើការសម្រេចចិត្តក្នុងកម្រិតថ្នាក់ក្រោមជាតិ |

<table>
<tr><td>ដើមភាគតិច ត្រូវបានផ្តល់អំណាចម្ចាស់ការលើផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច រួមបញ្ចូលដើម្បីអោយសម្រេចបាននូវការលូតលាស់ដោយសមធម៌និងសិទ្ធិស្មើភាពគ្នា</td><td>និងថ្នាក់ ជាតិដើម្បីបង្កើនសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន នយោបាយ និងវប្បធម៌<br>• បង្កើនអោយដល់ ៥០% នៃស្ត្រីគោលដៅក្នុងការកាន់តួនាទីជាអ្នកដឹកនាំអង្គការកសិករ និងរចនាសម្ព័ន្ធរបស់សហគមន៍</td></tr>
<tr><td colspan="2" align="center">លទ្ធផលសម្រេចបានឆ្នាំ ២០១៩</td></tr>
<tr><td colspan="2">ក្នុងកំឡុងពេលរាយការណ៍ឆ្នាំ២០១៩នេះ មានការកែប្រែតិចតួចធៀបទៅនឹងទិន្នន័យគោលដែលបានរៀបចំឡើងដោយវីអេហ្វិក។ យ៉ាងណាក៏ដោយ ការអនុវត្តគម្រោងជាទូទៅនៅតែមានទំនាក់ទំនងគ្នាទៅនឹងគោលដៅជាយុទ្ធសាស្ត្រ និងគោលបំណងជាក់លាក់របស់គម្រោង ស្របតាមកម្មវិធីវីអេហ្វិករបស់ថ្នាក់តំបន់អាស៊ីអាគ្នេយ៍។ តាមការសង្កេតឃើញថាមានចំនួនស្ត្រីបានចូលរួមច្រើនក្នុងដំណើរការអនុវត្តគម្រោង យ៉ាងហោចណាស់ ៦០% ជាមធ្យម។ ម្យ៉ាងវិញទៀតបើទោះភាគរយចូលរួមរបស់ស្ត្រីខ្ពស់ជាងបុរសក៏ដោយ ប៉ុន្តែសំលែងរបស់ស្ត្រីនៅតែទាបនៅឡើយក្នុងការចូលរួមលើកជាទស្សនយោបល់ ដែលមើលទៅមិនទាន់អាចប្រកួតប្រជែងនឹងបុរសបាននៅឡើយ។<br>• ៣០%=៦០ នៃស្ត្រី១៧០នាក់ ក្នុងចំណោមគណកម្មការសហគមន៍កសិកម្មសរុប ៣៣៥នាក់បានចូលរួមក្នុងដំណើ ការកសាងផែនការ និងសមាហរណកម្មផែនការឃុំ ហើយព្រមទាំងពាំនាំការជជែកសន្ទនាពីបញ្ហាដែលបានលើកទៅកាន់ថ្នាក់ជាតិផងដែរ។<br>• ៥១%=១៧០នាក់នៃស្ត្រីក្នុងចំណោមថ្នាក់ដឹកនាំទាំង ៣៣៥នាក់ បានកាន់តួនាទីក្នុងជួរថ្នាក់ដឹកនាំ ក្នុងសហគមន៍កសិកម្ម២២ សហភាពសហគមន៍កសិកម្ម១ ក្រុមសន្សំ ២៥ និងក្រុមផលិត ២០ក្រុម នៃបណ្តាខេត្តគោលដៅទាំង៣មាន សៀមរាប ព្រះវិហារ ឧត្តរមានជ័យ។</td></tr>
<tr><td align="center">គោលបំណងរួម</td><td align="center">លទ្ធផលរំពឹងទុកសម្រេចឆ្នាំ២០១៩</td></tr>
<tr><td>ផ្តល់អំណាចម្ចាស់ការ ដល់កសិករខ្នាតតូច និងអង្គការមហាជន ក្នុងឃុំទាំង១៥ រវាងអន្តរខេត្ត សៀមរាប ឧត្តរមានជ័យ និងព្រះវិហារ ក្នុងការទាមទារសិទ្ធិស្របច្បាប់ពួកគេដើម្បីទទួលបានសេវាសេដ្ឋកិច្ច និងសង្គមកិច្ចដោយនិរន្តរភាព</td><td>▪ សំណើរឬផែនការអង្គការមហាជនចំនួន២២បានដាក់ចូលទៅក្នុងសមាហរណកម្មផែនការឃុំ ឬបានដាក់ស្នើទៅកាន់ដៃគូរគាំទ្រដែលមានសក្តានុពលរៀងរាល់ឆ្នាំ<br>▪ ៥០%នៃស្ត្រីគោលដៅគម្រោងបានចូលរួមដោយសកម្មក្នុងការធ្វើសេចក្តីសម្រេចលើផ្នែកសេវាសេដ្ឋកិច្ច និងសង្គមកិច្ចទាំងនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ<br>▪ អង្គការមហាជននីមួយៗអាចរកប្រាក់ចំណេញ១៥%ប្រឆ្នាំ<br>▪ ១០% នៃកិច្ចសន្យាទិញលក់របស់អង្គការមហាជនមានការកើនឡើងប្រចាំឆ្នាំ<br>▪ ១០ វេទិការពិគ្រោះ និងជជែកពិភាក្សាទៅលើគោលនយោបាយត្រូវបានរៀបំឡើងដោយអង្គការមហាជន<br>▪ ករណី៤៥ដែលជាកង្វល់កសិករត្រូវបានចងក្រងលើកស្នើដោះស្រាយ ហើយ៥០%នៃបញ្ហាឬកង្វល់ជុំវិញវិស័យកសិកម្មនិងការអភិវឌ្ឍសហគមន៍នេះត្រូវបានរាយការណ៍ថាបានដោះស្រាយរៀងរាល់ឆ្នាំ</td></tr>
<tr><td colspan="2" align="center">លទ្ធផលសម្រេចបានឆ្នាំ ២០១៩</td></tr>
<tr><td colspan="2">ក្នុងកំឡុងពេលនៃឆ្នាំដំបូងនៃការអនុវត្តគម្រោងជំហ៊ាន២នៃផែនការយុទ្ធសាស្ត្រ៥ឆ្នាំ ២០១៨-២០២២នេះ យើងសង្កេតឃើញថាលទ្ធផលដែលសម្រេចបានដោយការខិតខំប្រឹងប្រែងរួមគ្នារវាងអង្គការកែប្រែសហគមន៍ និងអង្គការវីអេហ្វិកប្រហែល២០%ប៉ុណ្ណោះ ដោយសារកត្តានៃការយឺតយ៉ាវក្នុងទម្លាក់ថវិកាអនុវត្តគម្រោងដែលត្រូវបានពន្យារហូតដល់ខែមេសាឆ្នាំ២០១៨ ទើបធ្វើអោយប៉ះពាល់ដល់ការអនុវត្តសកម្មភាពមិនបានរលូនតាមផែនការដែលមានលទ្ធផលសង្ខេបគឺ៖<br>• សហគមន៍កសិកម្ម ២២ បានរៀបចំផែនការជំនួញរបស់ខ្លួន ហើយបានបញ្ចូលផែនការទៅក្នុងសមាហរណកម្មផែនការថ្នាក់ឃុំរៀងខ្លួនៗ<br>• ៣០%=៥១នាក់ នៃចំនួនស្ត្រី១៧០នាក់ ក្នុងចំនោមគណកម្មការដឹកនាំសហគមន៍ ៣៣៥នាក់របស់សហគមន៍កសិកម្ម ក្នុងខេត្តទាំង ៣ ពួកគាត់បានចូលរួមក្នុងដំណើរការកសាងផែនការថ្នាក់ឃុំទាំងកម្រិតភូមិនិងឃុំ ដើម្បីត្រៀមបញ្ចូលកង្វល់ដែលជាបញ្ហាដើម្បីស្នើការគាំទ្រពីឃុំខ្លួន (ផ្អែកលើរបាយការណ៍យោងលើការចុះប្រជុំជាមួយគណកម្មការសហគន៍ ក្នុងកំឡុងពេលចុះត្រួតពិនិត្យប្រចាំឆ្នាំ)</td></tr>
<tr><td align="center">គោលបំណងជាក់លាក់</td><td align="center">លទ្ធផលរំពឹងទុកត្រូវសម្រេចឆ្នាំ២០១៩</td></tr>
</table>

| | |
|---|---|
| ទី១៖ជម្រុញផលិតកម្មកសិកម្មដែលអាចធន់ទ្រាំនឹងអាកាសធាតុដោយនិរន្តភាព | • ស្ត្រីមកពីតាមអង្គការមហាជនអាចទទួលបាននូវកសិកដ្ឋានបង្ហាញគម្រូពីកសិកម្មចម្រុះដើម្បីអាចសិក្សារៀនសូត្រនិងអនុវត្តផ្ទាល់ពីកសិដ្ឋានគម្រូដែលជោគជ័យនេះ<br>• រៀបចំកសិកដ្ឋានបង្ហាញគម្រូចំនួន១តាមសហគមន៍កសិកម្មទាំង២២ ដើម្បីបង្ហាញពីខ្សែចង្វាក់ផលិតកម្មទៅដល់សមាជិកសហគមន៍កសិកម្ម<br>• កសាងសមត្ថភាពសមាជិកអង្គការមហាជនលើប្រព័ន្ធកសិកម្មដែលអាចធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ<br>• ផ្សព្វផ្សាយព័ត៌មានជុំវិញក្របខណ្ឌច្បាប់ទៅលើសិទ្ធិកាន់កាប់ដីទៅដល់សមាជិកអង្គការមហាជន<br>• ជម្រុញអោយមានការទទួលបានការគ្រប់គ្រងកាន់កាប់ដីដោយសុវត្ថិភាពដល់សមាជិកអង្គការមហាជន<br>• ស្ត្រីបានចូលរួមសម្រេចចិត្ត និងសំដែងនូវតម្រូវការពួកគាត់ទៅលើសិទ្ធពីសុវត្ថិភាពកាន់កាប់ប្រើប្រាស់ដីធ្លី<br>• ស្ត្រីជាកសិករមានការកើនឡើងក្នុងការទទួលបានសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មហើយនឹងធនធានគាំទ្រ<br>• ផលិតផលក្នុងស្រុកដែលកសិករផលិតបានត្រូវបានធ្វើការចុះបញ្ជីអត្តសញ្ញាណកម្ម |

| លទ្ធផលសម្រេចបានឆ្នាំ ២០១៩ |
|---|
| • សរុប៤១៩នាក់(៧០%=២៩២ជាស្ត្រី) ទទួលបានចំនេះដឹងលើប្រព័ន្ធកសិកដ្ឋានដំណាំចម្រុះហើយនឹងអាចយកបច្ចេកទេសទៅអនុវត្តដែលអាចបន្សុំនឹងការប្រែប្រួលអាកាសធាត។ យើងសង្កេតឃើញថាយើងសម្រេចបាន១២៤%លើសពីផែនការបើធៀបទៅនឹងសូចនករក្នុងឆ្នាំនេះ<br>• មានកសិដ្ឋានគម្រូ៧ក្នុងចំនោម៩មានដំណើរការល្អក្នុងខេត្តសៀមរាប<br>• មានក្រុមផលិត២០ក្រុមបានចងក្រង(មានសមាជិកសរុប៩២នាក់ ហើយ៨០%ជាស្ត្រី) ក្នុងនោះមានប្រភេទផលិតផលសំខាន់៣ប្រភេទដែលក្រុមធ្វើការផលិតផ្គត់ផ្គង់ខ្សែចង្វាក់ផលិតកម្មដូចជា អង្ករ មាន់ ហើយនឹងបន្លែ ត្រូវបានកំណត់យកសម្រាប់ក្នុងខេត្តសៀមរាប ឧត្តរមានជ័យ<br>• ៥០%=១១សហគមន៍កសិកម្មក្នុងចំនោម ២២បានធ្វើការកំណត់ប្រភេទផលិតផលក្នុងខ្សែចង្វាក់ផលិតកម្ម ដូចជា ស្រូវអង្ករ បន្លែ មាន់ និងសាច់ជ្រូក ហើយសហគមន៍កសិកម្ម១១ក្នុងចំនោម២២នៃ៣ខេត្តនេះបានភ្ជាប់ទំនាក់ទំនងគ្នាយ៉ាងរឹងមាំជាមួយសមាជិកក្នុងការជម្រុញការប្រភេទផលិតផលរបស់ពួកគេទៅកាន់ខ្សែចង្វាក់ផលិតកម្មទីផ្សារ។ ក្នុងនោះក៏មានជាអ្នកប្រមូលទិញ និងតំណាងស្ត្រីជាសហគ្រិនដែលបានទទួលនូវការកសាងសមត្ថភាពក្នុងការភ្ជាប់ផលិតផលទៅកាន់ទីផ្សារ។<br>• សរុប ៣០១នាក់ ក្នុងនោះស្ត្រី២២១ទទួលបាននូវវគ្គបណ្តុះបណ្តាលទៅលើបច្ចេកទេសការធ្វើកសិកម្មដែលអាចធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុ វាស្មើនឹង១៥%ធៀបទៅនឹងសូចនករ។ ហើយ៣៥%=១០៥នាក់ទទួលបានវគ្គបណ្តុះបណ្តាលដែលយកទៅអនុវត្តលើដំណាំបន្លែនិងការចិញ្ចឹកង្កែប។<br>• សរុបមាន១៦៣នាក់(១២៦នាក់=៧៧%ជាស្ត្រី) បង្កើនចំណេះដឹងដោយទទួលបាននូវព័ត៌មានផ្សព្វផ្សាយស្តីពីសិទ្ធិស្រប់ច្បាប់កាន់កាប់ដីធ្លី<br>• បញ្ហាដីធ្លី២ករណីក្នុងសហគមន៍កសិកម្ម២នៅឧត្តរមានជ័យ១បានដោះស្រាយរួច ហើយ១ករណីទៀតកំពុងដាក់ពាក្យបណ្តឹងទៅតុលាការ<br>• ៧៩%=៤២៣នាក់នៃស្ត្រីចំនោមអ្នកចូលរួមសរុប៥៣៤នាក់បានយល់ដឹងពីសិទ្ធិប្រើប្រាស់កាន់កាប់ដីធ្លី និងប្រភពនៃទំនាស់តាមរយៈការសហការផ្សព្វផ្សាយជាមួយអាជ្ញាធរនិងជំនាញតាមខេត្តគោលដៅរបស់ពួកគេ។ ក្នុងនោះមាន ៨០%=១៦៧នាក់ជាស្ត្រីក្នុងចំណោមអ្នកចូលរួម២០៩នាក់ក្នុងការជជែកជាមួយអាជ្ញាធរមូលដ្ឋានអំពីដំណោះស្រាយលើវិវាទដីធ្លី។<br>• ១៣២នាក់ជាស្ត្រីក្នុងចំនោមសរុប១៦៥នាក់ ទទួលបាននូវការអនុវត្តគោលការកសិកម្មល្អ និងបច្ចេកទេសកសិកម្មទំនើប<br>• ផលិតផលកសិកម្ម១ត្រូវបានកំណត់អត្តសញ្ញាណ "ស្រូវផ្ការំដួល" សៀមរាបអង្ករ ដើម្បីត្រៀមស្នើសុំចុះបញ្ជីរ |

<table>
<tr><td>ទី២៖ពង្រីការទទួលបាននូវការគាំទ្រដល់មនុស្សភេទដែលរងគ្រោះ និងការទទួលបានសេវាហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន</td><td>• ស្ត្រីទទួលបាននូវការកសាងសមត្ថភាពលើមូលដ្ឋានគ្រឹះនៃការការគ្រប់គ្រងហិរញ្ញវត្ថុ<br>• ស្ត្រីទទួលបានការណែនាំផ្តល់ជូននូវបច្ចេកទេសដែលជួយសម្រួលដល់ស្ត្រីដែលទន់ខ្សោយ<br>• ចំនួនស្ត្រីដែលទទួលបានវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពនិងមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុដែលផ្តល់សម្បទានល្អមកពីស្ថាប័នហិរញ្ញវត្ថុដែលមានសក្តានុពល<br>• សមាជិកអង្គការមហាជនជាស្ត្រីអាចកាន់តែសកម្មក្នុងការចូលរួមសម្រេចចិត្តជាមួយប្តី<br>• តាមបណ្តាអង្គការមហាជនក្នុងគោលដៅគម្រោងមានគោលនយោបាយដើម្បីផ្តល់ផលប្រយោជន៍ដល់ស្ត្រី<br>• អង្គការមហាជនក្នុងគោលដៅគម្រោងអាចមានលទ្ធភាពទទួលបានឥណទានដែលមានការប្រាក់ទាបពីគ្រឹះស្ថានហិរញ្ញវត្ថុដូចជាធនាគារអភិវឌ្ឍជនបទ ឬគ្រឹស្ថានមីក្រូហិរញ្ញវត្ថុផ្សេងៗ<br>• អំពីហឹង្សាលើស្ត្រីត្រូវបានកាត់បន្ថយ</td></tr>
<tr><td colspan="2">លទ្ធផលសម្រេចបានឆ្នាំ ២០១៩</td></tr>
<tr><td colspan="2">• ២៦៥នាក់(១៨៩=៧១%ជាស្ត្រី)បានចូលរួមប្រជុំតាមភូមិហើយនឹងទទួលវគ្គបណ្តុះបណ្តាលពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងហិរញ្ញវត្ថុ និងរបៀបទទួលបានឥណទានដែលសមស្រប។<br>• ឧបករណ៍ស្តីពីទស្សនទានយែនឌ័រ និងផែនទីបង្ហាញផ្លូវយែនឌ័រត្រូវបានផ្តល់ជូនស្ត្រីសហគមន៍គោលដៅ<br>• ស្ត្រី៥០នាក់បានទទួលនូវសេវាហិរញ្ញវត្ថុពីសហគមន៍កសិកម្ម និងមីក្រូហិរញ្ញវត្ថុ<br>• ស្ត្រី១២នាក់ដែលបានបណ្តុះបណ្តាលលើផែនទីបង្ហាញផ្លូវយែនឌ័របានលើកទឹកចិត្តអោយពួកគាត់មានផែនការគ្រួសារដើម្បីធ្វើការវាស់វែងពីការផ្លាស់ប្តូរតួនាទីនៃយែនឌ័រនិងទំនាក់ទំនងក្នុងគ្រួសារ<br>• តំណាងសហគមន៍កសិកម្ម៣បានរាយការណ៍ថាពួកគេបានទទួលឥណទានពីមីក្រូហិរញ្ញវត្ថុ IDEMUTSU and ACLEDA Bank<br>• ៩៦នាក់(៥៣=៥៥%ជាស្ត្រី) បានចូលរួមក្នុងដំណើរការផ្សព្វផ្សាយលើកកំពស់ការយល់ដឹង ហើយនឹងការប្រជុំដោយអង្គការCTOសហការជាមួយក្រុមប្រឹក្សាឃុំក្នុងតំបន់គោលដៅ អំពីបញ្ហាអំពើហឹង្សាក្នុងគ្រួសារ ឬលើស្ត្រី។<br>• មាន១៥ករណីរាយការណ៍តាមរយៈសហគមន៍កសិកម្ម១៥អំពីអំពើហឹង្សាលើគ្រួសារត្រូវបានដោះស្រាយ</td></tr>
<tr><td>ទី៣៖ ជម្រុញស្ត្រីជាសហគ្រិនភាព</td><td>• កសិកដ្ឋានគម្រូបង្ហាញពីគោលការណ៍សរីរាង និងកសិដ្ឋានបែប ការពារបរិស្ថានត្រូវបានរៀបចំ១កន្លែងដោយមានការគាំទ្របច្ចេ កទេសនិងឯកភាពពីមន្ទីរកសិកម្មខេត្ត<br>• កសិករទទួលបានការបណ្តុះបណ្តាលពីគោលការណ៍ដំណាំ សរីរាង្គនិងកសិដ្ឋានបែបការពារបរិស្ថាន<br>• កសិករទទួលបានការបណ្តុះបណ្តាលពីគោលការណ៍រៀបចំដំណាំដែលសន្សំសំចៃទឹកដើម្បីសម្របទៅនឹងការប្រែប្រួលអាកា សធាតុ (លក្ខខ័ណ្ឌទឹកភ្លៀងមិនគ្រប់គ្រាន់)<br>• កសិករមានចំណេះដឹងពីការសន្សំសំចៃទឹក ហើយចំនួនស្រះទឹកឬប្រព័ន្ធរក្សាស្តុកទឹកត្រូវបានបង្កើន៣០%ធៀបពីមុន<br>• ផលិតកម្មដំណាំ ហើយនឹងបច្ចេកទេសប្រើប្រាស់ជីកំប៉ុសនិងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតចង្រៃបែបធម្មជាតិកើនឡើង ៣០% ធៀបនឹងពេលមុន</td></tr>
<tr><td colspan="2">លទ្ធផលសម្រេចបានឆ្នាំ ២០១៩</td></tr>
</table>

កសិករតែងតែខ្វះមូលដ្ឋានចំណេះដឹងទៅលើជំនញប្រើប្រាស់ និងគ្រប់គ្រងទឹកលើកសិដ្ឋានដំណាំបានអស់សក្តានុ ពលដើម្បីបម្រើការស្រោចស្រព្វតាមរូបភាពដែលសន្សំសំចៃទឹក ក៏ដូចជាវិធីបំលែងកាកសំណល់អោយទៅជាមាន ប្រយោជន៍ក្នុងវិស័យកសិកម្ម។ ពួកគាត់សុខចិត្តទិញផលិតផលស្រាប់ដែលខ្វះខ្វាយថវិកាហើយជារបស់មានសារ ធាតុគីមីគ្រោះថ្នាក់ក៏ដោយជាជាងកែច្នៃ របស់ធនធានដែលមានស្រាប់អោយមានប្រយោជន៍។ ដូច្នេះគម្រោងបានផ្ត ល់វគ្គបណ្តុះបណ្តាលមានប្រយោជន៍ជាច្រើនទៅដល់ថ្នាក់ដឹកនាំរបស់សហគមន៍កសិកម្មទាំង១២ ដើម្បីអោយពួក គាត់អាចបន្តផ្សព្វផ្សាយចែករម្លែកទៅកាន់សមាជិករបស់គាត់ពេលក្រោយ។ ជាញឹកញាប់សមាជិកដែលទិញជីពីស ហគមន៍តែងតែសួរសំនួរពីរបៀបប្រើប្រាស់ជី ប៉ុន្តែពេលខ្លះយើងសង្កេតឃើញថាអ្នកទទួលខុសត្រូវគ្រប់គ្រងជំនួញ ជីនេះមិនទាន់បានឆ្លើយសំនួររបស់អ្នកប្រើប្រាស់បានត្រឹមត្រូវនៅឡើយ។ ជាការឆ្លើយតបនឹងក្តីកង្វល់នេះ គម្រោង បានទាក់ទងទៅក្រុមហ៊ុនដែលផ្គត់ផ្គង់ជី ហើយនឹងមន្ត្រីជំនាញពីមន្ទីរកសិកម្មមកផ្តល់វគ្គបណ្តុះបណ្តាលតាមសហគមន៍នីមួយៗ ទៅលើការគ្រប់គ្រងប្រើប្រាស់ជីនិងថ្នាំពុលកសិកម្មទៅដល់ថ្នាក់ដឹកនាំសហគមន៍២០៧នាក់ ក្នុងនោះ ស្ត្រី១២៥នាក់។ ក្រោយចប់វគ្គ ហើយមានការចុះតាមដានទៅលើករណីនេះ អ្នកចូលរួមភាគច្រើនបានបញ្ជាក់ថា វគ្គបណ្តុះបណ្តាលពីប្រធានបទនេះពិតជាជួយបង្កើនចំណេះដឹងពួកគាត់ដែលមាន៦០%នៃអ្នកចូលរួមបានយល់ពី ការប្រើប្រាស់ត្រឹមត្រូវ ហើយពួកគាត់អាចពន្យល់និងណែនាំទៅដល់កសិករដ៏ទៃពីវិធីប្រើប្រាស់ជីនិងថ្នាំគីមីបានត្រឹ មត្រូវតាមក្បួនបច្ចេកទេស។ ឯកសារបណ្តុះបណ្តាលមួយសេរីបានផ្តល់ជូន ជុំវិញប្រធានបទការដាំដុះបែបសរីរាង្គ និងការដាំដុះដែលធ្វើអោយប្រសើរដល់បរិស្ថាន ត្រូវបានរៀបចំដោយមានការឯកភាពពីមន្ទីរជំនាញផងដែរពោល គឺឯកសារចំលងមេរៀនត្រូវបានត្រូវបានផ្តល់ជូនដល់សិក្ខាកាមក្រោយវគ្គបណ្តុះបណ្តាល។ កសិករ២១០៦នាក់ ក្នុង ២៥០០នាក់មកពី១២សហគមន៍ និងក្រុមសន្សំប្រាក់ចាស់ថ្មី២៥ក្រុមក៏ទទួលបាននូវវគ្គបណ្តុះបណ្តាលនេះផងដែរ។ ក្រៅពីវគ្គនេះកសិករ ២១០៦នាក់ក្នុងចំនោម២៥០០នាក់ក៏ទទួលបានការបណ្តុះបណ្តាល និងការផ្សព្វផ្សាយអំពីប្រធានបទប្រសិទ្ធិភាពនៃការគ្រប់គ្រងនឹងប្រើប្រាស់ទឹកលើការដាំដុះ ដែលអាចសម្របទៅនឹងងការប្រែប្រួលអាកាសធាតុ។ ២៥%នៃកសិករ២១០៦នាក់ ដែលទទួលបានការបណ្តុះបណ្តាលរាយការណ៍មកថាមានការកើនឡើងនូវការ គ្រប់គ្រងសមត្ថភាពស្តុកទឹក ដូចជាការបង្កើនចំនួនពាងឬធុងទឹកដើម្បីប្រមូលទឹកភ្លៀងរក្សាទុកសម្រាប់ប្រើប្រាស់ ក្នុងខែប្រាំងហើយនឹងស្តារស្រះទឹកអោយមានសមត្ថភាពបង្រុង ទឹកដើម្បីបំលែងជាប្រព័ន្ធដំណក់ទឹកសម្រាប់ស្រោចស្រព្វសួនដំណាំ។ ៣០%នៃកសិករ២១០៦នាក់ដែលទទួលបានការបណ្តុះបណ្តាលមានការថយចុះការប្រើប្រាស់ ថ្នាំគីមី ឬបានប្រើជីនិងថ្នាំគីមីត្រឹមត្រូវតាមបច្ចេកទេស ហើយកសិករខ្លះងាកមកប្រើបច្ចេកទេសតាមបែបធម្មជាតិ ជំនួសវិញដោយបានបទពិសោធន៍ពីវគ្គបណ្តុះបណ្តាល។ កសិដ្ឋានបង្ហាញគម្រូពីការប្រើប្រព័ន្ធដំណក់ទឹកចំនួន ៩ កន្លែងត្រូវបានរៀបចំនៅតាមសហគមន៍ទាំង១២ ហើយតាមរយៈកសិដ្ឋានគម្រូនេះវាបានផ្តល់ការបង្ហាញទៅដល់កសិករ២២៥នាក់បានចូលរួមរៀនសូត្រយកបទពិសោធន៍ទៅលើទីវាលនៃកសិកដ្ឋានគម្រូនេះផ្ទាល់តែម្តង។

### បទពិសោធន៍ឬមេរៀនដែលរៀនសូត្រពីគម្រោង

ចរន្តជំនួញបែបសហគមន៍កសិកម្មគឺកំពុងមានសក្តានុពល ប៉ុន្តែសហគមន៍តាមតំបន់គោលដៅហាក់មានសំទុះឃើ តដើម្បីចាប់យកឱកាសនេះ។ តួយ៉ាងដូចជាផលិតកម្មកែច្នៃត្រីឆ្អើរដែលគម្រោងបានជួយជ្រោមជ្រែង ឃើញថាផលិតកម្មនៅមានបរិមាណតូចដែលធ្វើអោយទទួលបានប្រាក់កំរៃស្តួចស្តើង។ ហើយម្យ៉ាងវិញទៀតមុខជំនួញប្រភេទនេះ ងាយអ្នកដ៏ទៃដែលមានធនធានច្រើនចម្លងយកទៅរកស៊ីដែរនៅពេលដែលពួកគាត់មើលឃើញពីឱកាសរបស់វា។ នេះជាការគម្រាមគម្ហែងយ៉ាងខ្លាំងសម្រាប់ការចាប់ផ្តើមមុខជំនួញរបស់សហគមន៍ ស្រដៀងគ្នាចឹងដែរ មុខរបរទិញ លក់ស្រូវរបស់សហគមន៍ ដូចជាសហគមន៍នៅសំរោងយា ដោយធ្វើការប្រមូលទិញស្រូវពីសមាជិកក្នុងឆ្នាំ២០១៥ ក្នុងកម្រិតសមត្ថភាពតូចតាចហើយកែច្នៃយកទៅលក់ដើម្បីបង្កើនប្រាក់ចំណេញ។ មើលឃើញរបៀបរកស៊ីនេះថា កាក់កបមានទីផ្សារ ឈ្មួញក្នុងតំបន់គោលដៅក៏ចាប់ផ្តើមប្រមូលទិញពីកសិករដែលមិនមែនជាសមាជិកសហគមន៍ ហើយកែច្នៃមកលក់ប្រកួតជាមួយសហគមន៍ ហើយឈ្មួញមានទុនបង្វិលច្រើនដែលអាចទូទាត់អោយកសិករដែលលក់ស្រូវបានភ្លាមៗ ហើយពេលខ្លះឈ្មួញបានកក់លុយអោយមុនក៏មាន។ កត្តានេះជាឧបសគ្គដែលរារាំងមិនអោយកសិករចាប់អារម្មណ៍មកចូលរួមក្នុងជំនួញរបស់សហគមន៍ ហើយមានទាំងសមាជិកសហគមន៍ក៏បានចាកចេញហើយរត់ទៅលក់ស្រូវអោយឈ្មួញកណ្តាលវិញដដែល។ យ៉ាងណាក៏ដោយ គម្រោងនៅតែអាចមានលទ្ធភាពជួយដល់ សហគមន៍ដើម្បីប្រកួតជាមួយនឹងឈ្មួញសម្រាប់ការរកស៊ីយូរអង្វែង ដោយជួយអោយសហគមន៍មានឯកទេស ដូចជារៀបចំផលិតផលអោយមានផ្លាកសញ្ញាសំគាល់ផលិតផលត្រឹមត្រូវ។ ពង្រីកសមត្ថភាពដើម្បីភ្ជាប់ទៅក្រុមហ៊ុន ដែលប្រមូលទិញផលិតផលផ្ទាល់តាមរូបភាពបញ្ជាទិញឬដោយកក់ប្រាក់ជាមុន។ គម្រោងក៏គិតបានពិចារណាជួយ ដល់ការវេចខ្ចប់ដែលអាចនាំនាំទៅកាន់ទីផ្សារបាន។ ហើយគម្រោងមើលឃើញថា មានចំណេះដឹងតែលើការដាំដុះ តែប៉ុណ្ណឹងមិនគ្រប់គ្រាន់ដើម្បីផ្លាស់ប្តូរជីវភាពនិងសេដ្ឋកិច្ចកសិករក្រីក្របានឡើយ ប៉ុន្តែកសិករក្រីក្រត្រូវធ្វើសមាហរណកម្មចូលទៅក្នុងក្រុមឬប្រព័ន្ធ ដើម្បីអោយពួកគាត់អាចរៀនសូត្រហើយនឹងជួយគ្នាទៅវិញទៅមក និងរួមកម្លាំងគ្នា ដើម្បីមានសម្លេងគ្រប់គ្រាន់ដើម្បីជជែករកផលប្រយោជន៍ អោយក្រុម។ ឧបករណ៍ HRBA ក្នុងបរិបទនេះពិតជាអាច ក្លាយជាឧបករណ៍ពង្រឹងអំណាចផ្នែកសង្គមសម្រគ្រួសារក្រីក្រ នៅពេលដែលពួកគាត់ យល់

| |
|---|
| ពីតម្រូវការដែលពួកគា ត់គួត្រូវបានស្នើឡើងដើម្បីអោយពួកគាត់អាចបន្តដំណើរទៅមុខបាន។ ជាការសន្និដ្ឋានរួម គម្រោងបានរៀនសូត្រថា មានចំណេះជំនាញផ្នែកកសិកម្មតែម្យ៉ាងគឺមិនគ្រប់គ្រាន់ឡើយ (បើយោងទៅលើការពង្រឹងសមត្ថភាពសេដ្ឋកិច្ច) កសិករពិតជាមិនអាចធ្វើការផ្លាស់ប្តូរជីវភាពនិងសេដ្ឋកិច្ចពួកគាត់បានដោយប្រសិទ្ធិភាពទេ ប៉ុន្តែមានតែធ្វើការបញ្ចូ លគ្នារវាងចំណេះជំនាញទៅនឹងការប្រើប្រាស់សិទ្ធិរបស់ពួកគាត់អោយបានពេញលេញ (យោងទៅលលការពង្រឹង សមត្ថភាពផ្នែកសង្គមកិច្ច) ទើបកសិករអាចធ្វើការផ្លាស់ប្តូរនិងកែលំអរស្ថានភាពជីវភាពនិងសេដ្ឋកិច្ចរបស់ពួកគាត់ បានដោយប្រសិទ្ធិភាពនិងនិរន្តភាព។ |

## ២.ខេត្តឧត្តរមានជ័យ

### ១.គម្រោងមេ (LRP)

| គោលបំណងគំរោង | លទ្ធផលរំពឹងទុក |
|---|---|
| គោលបំណងជាយុទ្ធសាស្ត្រទី១៖ នៅបំណាច់ឆ្នាំ២០១៩សន្តិសុខស្បៀងកសិករខ្នាតតូចចំនួន៩៣២គ្រួសារក្នុង ភូមិគោលដៅចំនួន២៣នៃឃុំចំនួន៦និង៤ស្រុកត្រូវបានកែលំអរជីវភាពរស់នៅអោយប្រសើរឡើងជាងមុន។ | លទ្ធផល.១.១: កសិករខ្នាតតូច ទាំងស្ត្រី និងបុរស ចំនួន ៤០១ នាក់ក្នុង នោះ មានស្ត្រីចំនួន ៣០១នាក់ ក្នុងឃុំចំនួន៣នៃខេត្តឧត្តរមានជ័យទទួល បានការរស់នៅប្រសើរឡើងតាមរយៈការគ្រប់គ្រងលើក្រុមសន្សំ ធនាគារស្រូវ កសិករគំរូ និងបង្កើនសមត្ថភាពសហគមន៍ដើម្បីអោយមានភាព ធន់នឹងគ្រោះមហន្តរាយ និងស្វែងរកការគាំទ្រធនធានសេវាកម្ម បញ្ហាកសិកម្ម ត្រូវបានដោះស្រាយដោយមន្ទីរកសិកម្ម ឆ្លើយតបនឹងកសិកម្មនិ រន្តរភាពដែលធនទ្រាំនឹងការប្រែប្រួលអាកាសធាតុ។ |
| | លទ្ធផល.១.២: ៦០%នៃសមាជិកសហគមន៍ព្រៃឈើទាំងបីសហគមន៍ សរុប៤,៨៣៩នាក់ស្ត្រី/២,៣៣២នាក់ និងបណ្តាញសហគមន៍ព្រៃឈើទាំង១៣ ធ្វើការគ្រប់គ្រងថែរក្សានិងដកហូតធនធានពីព្រៃសហគមន៍ ប្រកបដោយ និរន្តភាព។ |
| | លទ្ធផល.១.៣: ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដីសម្បទានសេដ្ឋកិច្ចចំ នួន២២១គ្រួសា (១០៩០ហិកតា)ដែលមិនទាន់មានការដោះស្រាយអាចស្វែងរកការគាំទ្រពីរដ្ឋាភិបាលនិងដំណោះស្រាយសមស្របដោយសន្តិវិធី |
| | លទ្ធផល.១.៤: ប្រជាពលរដ្ឋដែលរងផលប៉ះពាល់៣៧៣គ្រួសារពីក្រុមហ៊ុន Synohydro នឹងមានសម្ថភាពយល់ដឹងពីសិទ្ធិនានារបស់ខ្លួនដែលមានចែង ក្នុងច្បាប់ អាចធ្វើសកម្មភាពស្របច្បាប់ស្វែងរកការគាំទ្រពីរដ្ឋាភិបាលដើម្បី ទទួលបានដំណោះស្រាយដោយសន្តិវិធី។ |
| គោលបំណងជាយុទ្ធសាស្ត្រទី២៖ នៅបំណាច់ឆ្នាំ២០១៩ កុមារចំនួន ២,៨៤១ នាក់/កុមារី១,៣១៨នាក់ស្ថិត នៅក្នុងឃុំចំនួនបីទទួលបានការអប់រំនៅថ្នាក់មូលដ្ឋានត្រឹមថ្នាក់ ទី៦ប្រសើរជាងមុន។ | លទ្ធផលទី២.១៖ កុមារចំនួន ២,៨៤១នាក់/កុមារី១,៣១៨នាក់ នៃឃុំសំរោង បន្សាយរាក់ និងគោកខ្ពស់ទទួលបានការសិក្សា បរិយាកាសនៃការសិក្សា ប្រសើរជាងមុនតាមរយៈក្លឹបកុមារ និងការលើកកំពស់សិទ្ធិក្នុងសាលារៀន |
| | លទ្ធផលទី២.២: គណៈកម្មការទ្រទ្រង់សាលាទាំង២០សាលា បានអនុវត្ត តួនាទី និងការទទួលខុសត្រូវក្នុងសាលារៀនប្រសើរជាងមុន ហើយប្រជាជន រួមទាំងកុមារចំនួន៧០០នាក់/ស្ត្រី៤០០នាក់ បានយល់ដឹងពីពីការលើក កំពស់សិទ្ធិក្នុងសាលារៀន(PRS)។ |
| គោលបំណងជាយុទ្ធសាស្ត្រទី៣៖ នៅបំណាច់ឆ្នាំ២០១៩ ស្ត្រីជាមេដឹកនាំសហគមន៍ចំនួន៧៦នាក់ រួមទាំងសមាជិកសហគមន៍ ២០ ភូមិ និង ក្រុមប្រឹក្សាឃុំ នៅក្នុង ឃុំសំរោង បន្សាយរាក់ និងគោកខ្ពស់ នៃខេត្ត ឧត្តរមានជ័យ ចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តតួនាទីរបស់ខ្លួន។ | លទ្ធផល.៣.១:ស្ត្រីជាមេដឹកនាំសហគមន៍ចំនួន៧៦នាក់ និងក្រុមប្រឹក្សាឃុំ ដែលទទួលបន្ទុក(គកនក)៦នាក់ក្នុងឃុំសំរោង បន្សាយរាក់ និងគោកខ្ពស់ បានប្រើប្រាស់តួនាទីរបស់ខ្លួនក្នុងការចូលរួមអភិវឌ្ឍន៏ភូមិឃុំរបស់ពួកគាត់ |
| | លទ្ធផល.៣.២:សមាជិកសហគមន៍ចំនួន៤០០នាក់/ស្ត្រី៣០០នាក់ បានយល់ដឹងពីតួនាទីយេនឌ័រ និងតួនាទីភេទ។ |

សម្រាប់ឆ្នាំ២០១៩នេះគោលបំនងរួមនៃគម្រោងគឺចង់ឃើញ កសិករក្រីក្រ៩៣២គ្រួសារនៃគ្រួសារសរុបចំនួន ២,៣៣២ គ្រួសារនឹង ទទួលបានសន្តិសុខស្បៀងតាមរយៈការគ្រប់គ្រងព្រៃសហគមន៍។

សង្ខេបលទ្ធផលទី១៖ សមាជិកសហគមន៍មានការទប់ស្កាត់បទល្មើសព្រៃឈើជាប្រចាំចំនួន១៣ករណីដែលបទ ល្មើសទាំងនេះមានការរុករានដីព្រៃ ការឈូសឆាយ សង់លំនៅឋាន និងកាប់ឈើខុសច្បាប់។ មានការចូលរួមពី គណៈកម្មការសហគមន៍ព្រៃឈើចំនួន២១១នាក់ ក្នុងនោះស្ត្រីចំនួន៤នាក់។ បើប្រៀបធៀបឆ្នាំ២០១៦បទល្មើស មានការកើនឡើង៦ករណី ប៉ុន្តែគណៈកម្មការសហគមន៍ព្រៃឈើពួកគាត់នៅតែមានការខិតខំប្រឹងប្រែងសហ ការណ៍ជាមួយអាជ្ញាធរពាក់ព័ន្ធ ជាពិសេសរដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់ និងមន្ទីរកសិកម្មខេត្តឧត្តរមានជ័យ ក្នុងការទុបស្កាត់បទល្មើស។ សមាជិកសហគមន៍នៅតែអាច ថែរក្សា គ្រប់គ្រង អភិរក្សសហគមន៍៣ (សហគមន៍ព្រៃឈើរំដួលវាសនា ភ្នំដងរ៉ែកសម្រែកព្រៃស្រស់ និងរតនរុក្ខា)ដែលជាតំបន់គោលដៅផ្ទាល់របស់គម្រោង មានផ្ទៃដីសរុប **20,345**ហិកតា។ មានសមាជិកសរុប ២,៣៣៤ គ្រួសារចូលទៅរកអនុផលព្រៃឈើជាប្រចាំដូចជា៖ ជីកដំឡូង បេះផ្សិត រកឃ្មុំ ជីកទំពាំង ឬស្សី ស្បូវ បេះបន្លែព្រៃ ចកអណ្តើក ក្បុក បន្លែព្រិច ស្តៅ វាំង អុស។ល។ សមាជិកសហគមន៍ប្រហែល៣០០គ្រួសារមានដីស្រែ និងចំការ ក្នុងព្រៃសហគមន៍ដែលពួកគាត់ទទួលផលស្រូវ និងដំឡូងមី ជារៀងរាល់ឆ្នាំ និងប្រហែល៥០គ្រួសារ ក្នុងចំណោម៣០០គ្រួសារ ប្រកបរបរនេសាទ ក្នុងព្រៃសហគមន៍ សម្រាប់បង្កើនប្រាក់ចំណូលសម្រាប់ចិញ្ចឹមជីវភាពគ្រួសារជាប្រចាំ។

សម្រាប់ឆ្នាំ២០១៩ មានការប្រជុំបណ្តាញសហគមន៍ព្រៃឈើចំនួន៤ដង ដើម្បីរៀបចំផែនការបន្តក្នុងការ ការពារព្រៃសហគមន៍។ បណ្តាញសហគមន៍បានដាក់ពាក្យបណ្តឹងចំនួន០៤ដង ទៅមន្ទីរកសិកម្ម និងខណ្ឌ រដ្ឋបាលព្រៃឈើឧត្តរមានជ័យ និងទៅក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ ដើម្បីស្វែងរកការគាំទ្រ និងដំណោះស្រាយ តែពុំទទួលបានលទ្ធផលផលល្អ។ ប៉ុន្តែតំណាងគណៈកម្មការសហគមន៍ ព្រៃឈើទាំង១២នៅតែព្យាយាមជួបគ្នា។ យ៉ាងហោចណាស់រៀងរាល់៣ខែម្តង ដើម្បីប្រជុំពិគ្រោះយោបល់គ្នា សម្រាប់ការស្វែងរកដំ ណោះស្រាយរួម និងសុំការផ្តល់ យោបល់ពីនាយខណ្ឌរដ្ឋបាលព្រៃឈើឧត្តរមានជ័យ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាតខេត្ត។ ទោះជាមានបទល្មើសកើតឡើងគ្រប់រូបភាពយ៉ាងណាក៏ដោយក៏សហគមន៍ព្រៃ ឈើទាំង១២ នៅតែរក្សាផ្ទៃដីបានព្រៃឈើ សហគមន៍បានចំនួន៤៦,៩៧៩ ហិកតា។ ដែលមានសមាជិកយ៉ាង ហោចណាស់ ៣,០៦៥គ្រួសារ គឺស្មើនឹង៤០ភាគរយនៃសមាជិកសរុប ទទួលបាននូវសិទ្ធ ក្នុងការដកហូតអនុផលព្រៃឈើគ្រប់ប្រភេទជាប្រចាំ។ នៅឆ្នាំ២០១៨ សហគមន៍ចំនួន០៦ ដែលកំពុងមានបញ្ហាប្រឈមខ្លាំង រួមមាន៖១-អណ្តូងបរ ២-ដុងបេង ៣-រំដួលវាសនា ៤-សាមគ្គីសង្គ្រោះព្រៃឈើ ៥-ក្បាលអូរសូភីគីរីព្រៃស្រោង ៦-រតនរុក្ខា នឹងលើកផែនការដាក់ពាក្យ បណ្តឹងទៅ តុលាការចំពោះបទល្មើសព្រៃឈើដែលពួកគាត់កំពុងជួបប្រទះ ពិសេសករណីការរុករានដីព្រៃធ្វើជា កម្មសិទ្ធ និងការកាប់ឈើសំណង់ និងកាប់ឈើធ្វើអុសធ្យូងជាដើម ។ល។

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដែលទើបជាប់ឆ្នោតចំនួន៤៥នាក់ក្នុងនោះចំនួន០៦នាក់ជាស្ត្រីបានយល់ដឹងពីច្បាប់ ស្តីពីព្រៃឈើនិងអនុក្រិតស្តីពីការបង្កើតសហគមន៍ព្រៃឈើ លើសពីនេះទៀត ពួកគាត់បានចូលរួម សកម្មក្នុងការ ទប់ស្កាត់ បទល្មើសក្នុងព្រៃសហគមន៍របស់ពួកគាត់ តាមរយៈការចុះល្បាត់ព្រៃ។ លើសពីនេះ គម្រោងបានសម្របសម្រួលកាយប្រឡាយធ្វើព្រំប្រទលព្រៃសហគមន៍ចំនួន០២សហគមន៍ ដែលមាន ប្រវែងសរុបចំនួន ១,៥២៨ ម៉ែត្រ ក្នុងនោះ ទទឹងមានចំនួន១ម៉ែត្រ និងជម្រៅចំនួន១ម៉ែត្រ ដែលជាព្រំប្រទល់ របស់សហគមន៍រតនរុក្ខានិងសហគមន៍ភ្នំដងរ៉ែកសម្រែកព្រៃស្រស់។ ការជីកប្រឡាយព្រំប្រទល់ព្រៃសហគមន៍នេះ បានផ្តល់អត្ថប្រយោជន៍ដ៏សំខាន់ដល់សហគមន៍ក្នុងការការពារព្រៃសហគមន៍របស់ពួកគាត់។ ប្រជាពលរដ្ឋ និងប្រជាសមាជិកសហគមន៍ មានការសប្បាយរីករាយជាខ្លាំង នៅពេលដែលបានប្រឡាយព្រំប្រទល់នេះ ព្រោះវាអាចបង្ហាញអំពីទីតាំង និងព្រំដែនកំណត់ព្រៃសហគមន៍យ៉ាងច្បាស់។ ជាក់ស្តែងនៅសហគមន៍ភ្នំដងរ៉ែកសម្រែកព្រៃស្រស់មានការថយចុះនូវបទល្មើសនៃការកាប់រានដីព្រៃ ហើយផ្ទៃដីចំនួន១៥ហិកតាដែលបានរុករាន ត្រូវបានផ្អាក និងឈប់បន្តការកាប់រុករានក្នុងព្រៃសហគមន៍ពីសំណាអ្នកភូមិខាងក្រៅ។ ចំណែកឯសហគមន៍ រតនរុក្ខា កំពុងតែមានការព្រួយបារម្ភណ៍ព្រោះមានប្រជាជនមកពីភូមិក្រៅ និងទាហ៊ាន៤២ ដោយពួកគាត់មក ធ្វើស្រែប្រហែលជាង១០០ហិកតា នៅក្នុងព្រៃសហគមន៍ ដែលកន្លងមកពួកគាត់បានធ្វើការរុករានពង្រីកក្បាលដី បន្ថែមខុសច្បាប់យ៉ាងអនាធិបតេយ្យ ដោយគ្មានការក្រែងការអោរច្បាប់ ។ ក្រុមការងាររបស់អង្គការកែប្រែសហគមន៍ បានសហការជាមួយសមាជិកសហគមន៍ អាជ្ញាធរដែនដីដាំឬស្សីផ្អែម យកទំពាំង សរុបចំនួន៣៦០ដើម ជាការផ្សាំ និងត្រៀមទុកពូជ សម្រាប់នាំយកទៅដាំតាមបណ្តោយ ព្រំប្រទល់ជុំ វិញព្រៃសហគមន៍ នៃសហគមន៍ព្រៃឈើរតនរុក្ខា និងសហគមន៍ព្រៃឈើភ្នំដងរ៉ែកសំរែកព្រៃស្រស់។ តាមការសង្កេត និងតាមដាន ការថែទាំកូនឬស្សីរបស់សហគមន៍កន្លងមក យើងឃើញថា៖ រហូតមកដល់ពេល

នេះកូន ឫស្សីនៅសរុប៣៤៥ដើម ហើយគណៈកម្មការគ្រប់គ្រងសហគមន៍បានភ្ជួរដីព័ទ្ធជុំវិញតំបន់ដាំឬស្សី ដើម្បីការពារ ភ្លើងឆេះព្រៃ ឬស្សីទាំងអស់ជាពូជ សម្រាប់ដាំបន្តនៅតាមព្រំប្រទល់ព្រៃសហគមន៍នឹងចែកជូនដល់សមាជិក សហគមន៍នៅពេលត្រូវការចង់ដាំយកទំពាំង ដើម្បីលក់សម្រាប់ប្រើប្រាស់ជាលក្ខណៈគ្រួសារ និងដើម្បីលក់យក ប្រាក់ចំណូល។តំណាងសហគមន៍ទាំង១៣បានជួបជាមួយអភិបាលរង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន០១លើក ដើម្បីរកដំណោះ ស្រាយលើបទល្មើសដែលកើតមានឡើងក្នុងព្រៃសហគមន៍កន្លងមក។ ក្នុងជំនួបនោះ លោកអភិបាលរងខេត្ត បានសន្យាថានឹងជួយប្រមូលបញ្ហាទាំងអស់របស់សហគមន៍ ដាក់ជូនដល់ឯកឧត្តមអភិបាលខេត្តពិនិត្យនិងដោះស្រាយនៅកំរិតខេត្ត រីឯបញ្ហាមួយចំនួនដែលមិនអាចដោះស្រាយនៅកំរិតថ្នាក់ខេត្តបាន នឹងត្រូវបញ្ជូនបន្តទៅ ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជួយដោះស្រាយបន្ថែម។ អភិបាលខេត្តបានលើកផែនការដើម្បីជួប ជាមួយសហគមន៍ទាំង១៣ តែរហូតដល់ពេលនេះមិនទាន់បានជួបនៅឡើយដោយសាររវល់រហូត។ នៅក្នុងឆ្នាំ២០១៨នេះ សហគមន៍ព្រៃឈើអណ្តូងបរ សហគមន៍ព្រៃឈើដុងបេង និងសហគមន៍ព្រៃឈើសាមគ្គី សង្គ្រោះព្រៃឈើគ្រោងផែនការផ្តិតមេដៃសមាជិកសហគមន៍ទាំងអស់ដាក់ជូនអភិបាលខេត្តជួយដោះស្រាយ។ នៅក្នុងខែធ្នូឆ្នាំ២០១៧កន្លងមកនេះមានសហគមន៍ព្រៃឈើ ចំនួន០៤រួមមាន៖ សហគមន៍ព្រៃឈើរំដួលវាសនា សហគមន៍ព្រៃឈើដុងបេង សហគមន៍ ព្រៃឈើអណ្តូងបរ និងសហគមន៍ព្រៃឈើក្បាលអូរសូភីគីរីព្រៃស្រោង បានដាក់ពាក្យបណ្តឹងទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួច ហើយ។ ប៉ុន្តែមិនទាន់បានទទួលដំណឹង ត្រប់មកវិញ ដូច្នេះយើងកំពុងរងចាំ និងបន្តតាមសួរព័ត៌មាននេះបន្ថែមទៀត ជាមួយក្រសួងកសិកម្ម។

ក្នុងឆ្នាំ២០១៨នេះ មានក្រុមសន្សំសរុបចំនួន២១ក្រុម ស្ថិតក្នុងភូមិគោលដៅចំនួន២០ភូមិ ក្នុងឃុំចំនួន០៤ឃុំ/ សង្កាត់ នៃក្រុងសំរោង និងស្រុកបន្ទាយអំពិល របស់ខេត្តឧត្រមានជ័យ។ ក្រុមទាំង២១ មានថវិកាសរុបចំនួន ១១៥,៧១២,៥០០រៀល ដែលមានសមាជិកសរុបចំនួន៤២៦នាក់ក្នុងនោះស្ត្រីចំនួន៣៦៩នាក់។ ទឹកប្រាក់សរុបដែលក្រុមបានផ្តល់កម្ចីឱ្យទៅសមាជិកក្រុមសរុបចំនួនន ១១៥,៧១២,៥០០ រៀលស្មើនឹងចំនួន៤២៦នាក់។ គ្រួសារពួកគាត់ខ្ចី៦ខែម្តងវិលតគ្នា ហើយប្រាក់ដែលនៅសល់ក្នុងក្រុមនីមួយៗ ពី ១00,000 ម៉ឺន ទៅ ១៥0,000ម៉ឺន មិនបានឱ្យកម្ចីសរុបចំនួន ២,១00,000 ទៅ ៣,១៥0,000រៀល។ កម្ចីដែលសមាជិក ទាំងអស់ខ្ចី ភាគច្រើនប្រើសម្រាប់ក្នុងគោលបំណងប្រើលើករបរដាំដំឡូងធ្វើស្រែ លក់ចាប់ហួយ កសិកម្ម ដាំបន្លែ ឈ្នួលភ្ជួរដី។ ៦ខែពួកគាត់សងម្តង រួចធ្វើពាក្យកំចីសាថ្មី មិនមានសមាជិកណាខ្ចីមិនបានសងទេ។ ក្នុងការសន្សំ មានការកើនឡើងជាប្រចាំ ដោយពួកគាត់មានការកាត់បន្ថយកម្ចីពីធនាគារ។ ប្រាក់ដើមឆ្នាំសរុបទាំង២១ក្រុមមាន២៩,៥៧0,000រៀលទឹកប្រាក់ចុងឆ្នាំមាន១១៥,៧១២,៥00រៀលមានការកើនឡើងសរុប៨៤,៣៩២,៥00រ

**សង្ខេបលទ្ធផលទី២៖**សម្រាប់ឆ្នាំ២០១៩ នេះស៊ីធីអូ បានប្រមូលសារក្មេងសរុប៦១២នាក់ ក្នុងនោះកុមារី ៣៥២នាក់។ បានផ្ញើបញ្ជីឈ្មោះ និងសាររបស់កុមារចំនួន៥៨២នាក់ (កុមារី៣៣៩នាក់) ទៅកាន់ការិយាល័យ របស់អង្គការអាក់សិនអេដ។ បានតាមដានស្ថានភាពកុមារធ្វើចំណាកស្រុកចំនួន៣០នាក់ (កុមារីចំនួន១៣នាក់) ដែលពួកគាត់ធ្វើចំណាកស្រុកតាមរូបភាពផ្សេងៗដូចជា៖ កុមារខ្លះធមហើយ ត្រូវទៅធ្វើការនៅប្រទេសថៃ និងខ្លះទៀតទៅធ្វើការនៅខេត្តផ្សេងៗ។ រីឯកុមការតូចខ្លះទៀតត្រូវធ្វើដំណើតាមឪពុក ម្តាយធ្វើចំណាកស្រុក ធ្វើការប្រកបរបរចិញ្ចឹមជីវិត្តនៅក្រៅខេត្ត ឬទៅប្រទសថៃ។ ការប្រជុំគ្រូស្ម័គ្រចឹត្តមានការចូលរួមចំនួន២៨នាក់ /២៤ស្ត្រី។ ដើម្បីជួយសម្របសម្រួលក្នុង កម្មវិធីកុមារ។ បានចែកសម្ភារៈក្លឹបកុមារចំនួន១០សាលា ដែលមានអ្នកចូលរួមសរុប១១៥ នាក់ស្រី៥៦នាក់ ដែលមានសាលាដូចជា សាលាបឋមសិក្សាដូនកែនភ្ញៀត បឋមសិក្សា សំរោង បឋមសិក្សាគោកគរ បឋមសិក្សាហ៊ុនសែនឆ្អើប បឋមសិក្សាបន្សាយរាក់ បឋមសិក្សាអូរទេង បឋម សិក្សាត្នោត បឋមសិក្សាពោធិវង្ស បឋមសិក្សាឈើស្លាប់ និងបឋមសិក្សាគោកខ្ពស់ថ្មី ។

**សង្ខេបលទ្ធផលទី៣៖**ការប្រជុំក្រុមប្រឹក្សាភិបាល បានលើកឡើងពី របាយការណ៍វឌ្ឍនៈភាពប្រចាំឆមាសទី១ នៃឆ្នាំ២០១៩របស់អង្គការកែប្រែសហគមន៍ និងពិភាក្សាដើម្បីកែសម្រួលគោលនយោបាយស្តីពីការគ្រប់គ្រង បុគ្គលិក និងគណៈគ្រប់គ្រងអង្គការ និងសំណើជ្រើសរើសប្រធានកម្មវិធី ដែលជានាយកស្តីទី និងពិភាក្សាកែសម្រួលគោលនយោបាយ ប្រាក់បៀវត្សន៍ (ប្រាក់បំណាច់មុខងារ និងប្រាក់បៀវត្សន៍ទីខែទី១៣) និងបច្ចុប្បន្នភាពម្ចាស់ជំនួយ និងប្រភពថវិកា និងលើកទិសដៅផែនការសកម្មភាពដែលត្រូវអនុវត្តបន្ត និងសេចក្តីថ្លែងអំណរគុណដល់ក្រុមប្រឹក្សាភិបាល ការត្រួតពិនិត្យនិងឆ្លុះបញ្ចាំងការអនុវត្តសកម្មភាពប្រចាំត្រីមាស។ អង្គការកែប្រែសហគមន៍មានកែតម្រូវលើការអនុវត្តគម្រោងមួយចំនួន មានការរៀបចំផែនការឆ្នាំ២០២០ និងមានចូលរួមសិក្ខាសាលាជាមួយអង្គការNEP, NGOs Forum,CCC ទទួលបានចំណេះដឹងថ្មីៗពីគោលការណ៍អប់រំនានា និងពត៌មានពី

| |
|---|
| ការគ្រប់គ្រងធនធានធម្មជាតិ និងដីធ្លី សម្រាប់គ្រឡប់មក អនុវត្តគម្រោងបន្តអោយមានប្រសិទ្ធិភាព។ |

**១.ពិព័ណ៌នាការរីកចំរើនរបស់គម្រោង**

លទ្ធផលទី១៖ សមាជិកសហគមន៍ព្រៃឈើទាំងបីសហគមន៍សរុប ៣,២២៦នាក់ ស្រ្តី ១,៥៥៥នាក់ និងបណ្តាញសហគមន៍ព្រៃឈើ ដែលមានសហគមន៍ចំនួន១៣ ធ្វើការគ្រប់គ្រង ថែរក្សា និងដកហូតធនធានពីព្រៃសហគមន៍ប្រកបដោយនិរន្តរភាព។

លទ្ធផលទី២៖ កុមារចំនួន៥៨១នាក់/កុមារី៣៣៨នាក់ស្ថិតនៅឃុំសំរោងបន្សាយរាក់និងគោកខ្ពស់មានការចូល រួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសហគមន៍ តាមរយៈ ការគូរសារ កម្មវិធីសប្បាយៗ ក្លឹបកុមារ និងការលើកកំពស់សិទ្ធិក្នុងសាលារៀន។

លទ្ធផលទី៣៖ អង្គការCTOជាស្ថាប័នដែលមានគណនេយ្យភាព និងតម្លាភាពចំពោះម្ចាស់ជំនួយ និងអ្នកទទួលផល

**I. សកម្មភាពធនធានធម្មជាតិ**

- សហការជាមួយអាជ្ញធរ និងរដ្ឋបាលព្រៃឈើដើម្បីទុបស្កាត់បទល្មើសក្នុងព្រៃឈើសហគមន៍។
- ប្រជុំបណ្តាញសហគមន៍ ថ្នាក់ខេត្ត មន្ទីរកសិកម្ម រដ្ឋបាលព្រៃឈើ និងអាជ្ញាធរមូលដ្ឋាន។
- គាំទ្រសកម្មភាពបណ្តាញក្នុងការដោះស្រាយបទល្មើសព្រៃឈើសរសេររបាយការណ៍ជួយសម្របសម្រួលសហគមន៍ផ្សេងៗទៀតទាំង១៣។
- ជួបជាមួយ ឃុំ ស្រុក ខេត្ត មន្ទីរកសិកម្ម ក្រសួងកសិកម្ម ក្នុងការដោះស្រាយបញ្ហាទាក់ទង សហគមន៍ ព្រៃឈើទាំង១៣។
- ចូលរួមវាទិកាសាធារណៈថ្នាក់ ឃុំ ស្រុក ខេត្ត។
- ស្រង់ស្ថិតិរណាយន្តតាមភូមិ និងសំណើរប្រើប្រាស់រណាយន្តទាក់ទងនឹងភូមិសហគមន៍ព្រៃឈើ។
- ជីកប្រឡាយបង្គោលព្រំប្រទល់ព្រៃសហគមន៍នៅសហគមន៍ព្រៃឈើទាំងបី។
- ដាក់ផ្ទាំងផែនទីតាមសាលាឃុំ និងទីតាំងសហគមន៍ព្រៃឈើ។
- គៀងគោសមាជិកសហគមន៍ក្នុងការដាំដំណាំយុទ្ធសាស្រ្តគ្រាប់ត្នោតឬស្សីការពារព្រំប្រទល់ព្រៃសហគមន៍
- បុណ្យខួបសហគមន៍ព្រៃឈើប្រចាំឆ្នាំ
- ធ្វើកិច្ចសន្យាអ្នកដែលមានដីអាស្រ័យផលក្នុងព្រៃសហគមន៍។
- ប្រជុំសហគមន៍ រវាងអាជ្ញាធរភូមិ ឃុំ ប្រចាំខែ
- បណ្តុះបណ្តាល និងផ្សព្វផ្សាយ វិទ្យុ ទូរទស្សន៍ សន្និសីទកាសែតពីច្បាប់ស្តីពីព្រៃឈើ និងអនុក្រិតស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ។
- ចូលរួមធ្វើផែនការវិនិយោគប្រចាំឆ្នាំ
- ទស្សនៈកិច្ចព្រៃដៃគូនៅពោធិសាត់

**II. ផ្នែកអប់រំ**

- ការសាងសង់កន្លែងលាងដៃសិស្ស
- សង់បណ្ណល័យនៅសាលាគោកខ្ពស់
- សាងសង់ប្រព័ន្ធទឹកស្អាត
- សាងសង់ឡដុតសំរាម
- សាងសង់រោងអាហារសិស្ស
- ធ្វើការផ្សព្វផ្សាយទូរលំទូរលាយអំពីថវិPB
- មាតាបិតាសិស្សគ្រូជួបគ្នា១ឆ្នាំ២ទៅ៣ដង
- សាងសង់របងសាលារៀន

- ទិញសំភារៈកីឡាសិស្ស
- រៀបចំសួរកុមារ
- រៀបចំកន្លែងបណ្ណាល័យដាក់សៀវភៅ

III. **ផ្នែកជីវិភាព**

- ប្រជុំធ្វើកិច្ចសន្យាជាមួយសមាជិកចាស់ដែលនៅជំពាក់ស្រូវនិងថវិកា
- ធ្វើការសាងសង់ជង្រុកថ្មីនិងរកកន្លែងទុកដាក់ជង្រុកអោយមានសុវត្ថិភាពនិងជួសជុលបន្ថែម
- ប្រជុំធ្វើការផ្សព្វផ្សាយក្នុងការប្រើប្រាស់ពូជដំណាំតាមតំរូវការទីផ្សារ
- ផ្តល់វគ្គបណ្តុះបណ្តាលដល់គណៈកម្មការនិងសមាជិកស្តីពីការគ្រប់គ្រងបញ្ជីស្នាមនិងសមាជិក
- អោយមាននិន្តរភាព រៀបចំរចនាសម្ព័ន្ធថ្មីនិងជ្រើសរើសគណៈកម្មការបន្ថែម
- បណ្តុះបណ្តាលពីការជ្រើសរើសពូជនិងការទុកដាក់ពូជ( ស្រូវ និងដំណាំ)

III. **របាយការណ៍ហិរញ្ញវត្ថុ**

<u>ខេត្តសៀមរាប</u>

| គម្រោង | ចំណូលប្រចាំឆ្នាំ | ចំណាយប្រតិបត្តិការ | ចំណាយកម្មវិធី | សមតុល្យឆ្នាំមុន | សមតុល្យ |
|---|---|---|---|---|---|
| WeEffect | 73,850.59 USD | 73,507.73 USD | 40,590.88 USD | 2,091.41 USD | 342.86 USD |
| PACT | 6,045.01 USD | 1,886.00 USD | 1,438.16 USD | 45.01 USD | 4,159.01 USD |

<u>ខេត្តឧត្តរមានជ័យ</u>

| គម្រោង | ចំណូលប្រចាំឆ្នាំ | ចំណាយប្រតិបត្តិការ | ចំណាយកម្មវិធី | សមតុល្យ |
|---|---|---|---|---|
| LRP | 52,585.81 USD | 48,010.66 USD | 40,111.00 USD | 4,575.15 USD |

IV. **ផែនការទិសដៅការងារបន្ត**

**<u>ខេត្តសៀមរាប</u>**

**<u>គម្រោងទី១៖</u>**

1-ស្រ្តីមកពីអង្គការសហគមន៍អាចទទួលបានការសិក្សាពីកសិដ្ឋានបង្ហាញដំណាំចម្រុះដែលជោគជ័យ
2-រៀបចំកសិដ្ឋានបង្ហាញគម្រូ ២២កន្លែងដែលស្របទៅនឹងខ្សែរសង្វាក់ផលិតកម្មដល់សមាជិកសហគមន៍កសិកម្ម
3-កសាងសមត្ថភាពកសិករជាសមាជិកសហគមន៍កសិកម្មពីកសិកម្មបន្សាំនឹងការប្រែប្រួលអាកាសធាតុ
4-ផ្សព្វផ្សាយពត៌មាន និងឯកសារគតិយុត្តិជុំវិញសិទ្ធិដីធ្លីដល់សមាជិកសហគមន៍កសិកម្ម
5-លើកកំពស់ការទទួលបាននូវសុវត្ថិភាពដីធ្លីរបស់សមាជិកសហគមន៍កសិកម្ម
6-ស្រ្តីអាចធ្វើការចូលរួមសម្រេចចិត្តសកម្មក្នុងការទាមទាសិទ្ធីដីធ្លីដោយការលើកកំពស់សមភាពយែនឌ័រ
7-កសិករជាស្រ្តីអាចទទួលបាននូវការផ្សព្វផ្សាយសេវាកម្មកសិកម្ម និងធនធាន
8-ផលិតផលសហគមន៍ដែលមានសក្តានុពលនឹងទទួលបានការចុះបញ្ជីរអត្តសញ្ញាណ
9-ស្រ្តីអាចទទួលបាននូវការកសាងសមត្ថភាពទៅលើមូលដ្ឋានចំណេះដឹងស្តីពីហិរញ្ញវត្ថុ
10-ណែនាំនូវបច្ចេកទេសបែបច្នៃប្រឌិតដែលផ្តល់ភាពងាយស្រួលដល់ស្រ្តី

12-ស្ត្រីជាសមាជិកសហគមន៍កសិកម្មអាចចូលរួមសម្រេចចិត្តយ៉ាងសកម្មជាមួយប្តី
13-សហគមន៍លើកគំនិតផ្តួចផ្តើមរៀបចំគោលនយោបាយដើម្បីផ្តល់ប្រយោជន៍ដល់ស្ត្រី
14-សហគមន៍អាចទទួលបានកំចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើម្បីយកទៅពង្រីកមុខជំនួញ
15-បុគ្គលិកគម្រោងនឹងទទួលបានការបណ្តុះបណ្តាលពីឧបករណ៍ GALS ហើយនឹងគាំទ្រសហគមន៍ដើម្បីកសាងឧបករណ៍ GALS ហើយនឹងអនុវត្តទៅដល់សមាជិកនិងសហគមន៍
16-បង្កើនការចូលរួមរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំតាមអង្គការសហគមន៍
17-អំពើហឹង្សាស្ត្រីត្រូវបានកាត់បន្ថយ

**គម្រោងទី២៖**

1-កសាងសមត្ថភាពជំនាញសហគ្រិនភាពដល់សហគ្រិននារីវ័យក្មេង និងយុវជន ១២៥នាក់ ក្នុងខេត្តសៀមរាប
2-បង្វិក និងប្រកួតប្រជែងសហគ្រិននារីវ័យក្មេងឆ្នើម ៥នាក់
៣-ចងក្រង និងបង្កើតមជ្ឈមណ្ឌលបណ្តាញសហគ្រិននារីវ័យក្មេងប្រចាំខេត្តសៀមរាប

**ខេត្តឧត្តរមានជ័យ**

**លទ្ធផល.1:សមាជិកសហគមន៍ព្រៃឈើទាំងបីសហគមន៍សរុប៣,២២៦នាក់ស្ត្រី/១,៥៥៥នាក់ និងបណ្តាញសហគមន៍ព្រៃឈើ ទាំង១៣ ធ្វើការគ្រប់គ្រង ថែរក្សានិងដកហូតផលធានពីព្រៃសហគមន៍ប្រកបដោយនិរន្តរភាព។**

1.1. សហការជាមួយអាជ្ញធរ និងរដ្ឋបាលព្រៃឈើ និងមានការចូលរួមពីយុវជនដើម្បី ទុបស្កាត់បទល្មើសក្នុងព្រៃឈើសហគមន៍។
1.2. ប្រជុំបណ្តាញសហគមន៍ ថ្នាក់ខេត្ត មន្ទីរកសិកម្ម រដ្ឋបាលព្រៃឈើ និងអាជ្ញាធរមូលដ្ឋាន។
1.3. គាំទ្រសកម្មភាពបណ្តាញក្នុងការដោះស្រាយបទល្មើសព្រៃឈើ និងដីព្រៃសហគមន៍ សរសេររបាយការណ៍ជួយសម្របសម្រួលសហគមន៍ផ្សេងៗទៀតទាំង១៣។
1.4. ជួបជាមួយ ឃុំ ស្រុក ខេត្ត មន្ទីរកសិកម្ម ក្រសួងកសិកម្ម ក្នុងការដោះស្រាយ បញ្ហាទាក់ទងសហគមន៍ព្រៃឈើ និងដីព្រៃសហកមន៍ទាំង១៣។
1.5. ចូលរួមវាទិកាសាធារណៈថ្នាក់ ឃុំ ស្រុក ខេត្ត។
1.6. ដឹកប្រឡាយបង្គោលព្រំប្រទល់ព្រៃសហគមន៍នៅសហគមន៍ព្រៃឈើទាំងបី(ភ្នំដងរ៉ែកសម្រែកព្រៃស្រស់ និងរតនរុក្ខា)
1.7. ដាក់ផ្ទាំងផែនទីសហគមន៍ព្រៃឈើតាមសាលាឃុំ និងទីតាំងសហគមន៍ព្រៃឈើ
1.8. គៀងគរសមាជិកសហគមន៍ក្នុងការដាំដំណាំយុទ្ធសាស្ត្រគ្រាប់ត្នោត និងឬស្សីក្នុងការ ការពារ ព្រំប្រទល់ព្រៃសហគមន៍។
1.9. គណៈកម្មការសហគមន៍ព្រៃឈើចូរួមប្រជុំជាមួយអាជ្ញាធរភូមិ ឃុំ ប្រចាំខែនៅសលាឃុំ/សង្កាត់
1.10. ចូលរួមធ្វើផែនការវិនិយោគប្រចាំឆ្នាំ
1.11. ធ្វើថ្នាលបណ្តុះកូនឈើ២សហគមន៍
1.12. វេទិការជួបជុំរឹតចំណងសាមគ្គីរវាងអង្គការកែប្រែសហគមន៍ ក្រុមបណ្តាញសហគមន៍ក្នុងតំបន់គោលដៅ និងអាជ្ញាធរ ឃុំ ស្រុក ខេត្ត បូកសុរបសមទ្ធិផលជោគជ័យប្រចាំឆ្នាំ

**លទ្ធផលទី២៖ កសិករក្រីក្រចំនួន៩៣២គ្រួសារ នឹងអាចមានជីវភាពរស់ នៅប្រសើរឡើងដើម្បីអាចជានា កាសិក្សារបស់កូនៗអោយបានយ៉ាងទាបថ្នាក់ទី៩តាមរយៈការគ្រប់គ្រងក្រុមសន្សំ ២១ក្រុម និងធនាគា ស្រូវចំនួន៨ក្រុម ដែលមានការសហការណ៍ជាមួយក្រុមប្រឹក្សាឃុំ សំរោង បន្សាយរាក់ កូនក្រៀល និងគោកខ្ពស់។**

2.1. វគ្គបណ្តុះបណ្តាលការចុះបញ្ជីស្មាមគណៈកម្មការសន្សំ និងធនាគារស្រូវដល់គណៈកម្មការថ្មី

2.2. តំណាងក្រុមប្រឹក្សាឃុំ និងតំណាងគណៈកម្មកាថ្នាក់ឃុំសហគមន៍បង្ហាត់បង្ហាញបន្ថែមជាប្រចាំ និងធ្វើការតាមដានឆ្លុះបញ្ចាំងដល់គណៈកម្មការក្រុមសន្សំ21ធនាគារស្រូវ8ក្រុម២ខែ ម្តង។

2.3. ប្រជុំឆ្លុះបញ្ចាំង១ឆ្នាំម្តង(ក្រុមសន្សំ២១ និងធនាគាស្រូវ ៨ និងកសិករគំរូ

2.4. ប្រជុំបណ្តាញសន្តិសុខស្បៀងថ្នាក់ជាតិ១ដង

**លទ្ធផលទី៣៖កុមារចំនួន ៦៦០នាក់/កុមារី៣៨៣នាក់ ស្ថិតនៅ ឃុំ សំរោង បន្សាយរាក់និងគោក ខ្ពស់មានការចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសហគមន៍ តាមរយៈ ការគូរសារ កម្មវិធីសប្បាយៗ ក្លឹបកុមារ និងការ លើក កំពស់សិទ្ធិក្នុងសាលារៀន។**

3.1. សកម្មភាពគូសារ អប់រំទូទៅតាមសាលារៀន (ថែមកុមារ៣០០នាក់ថ្មី)

3.2. ប្រជុំគ្រូស្មគ្រ័ចិត្តចំនួន២៦នាក់រៀងរាល់6ខែម្តង

3.3. សម្ភារៈគូសារកុមារ

3.4. កម្មវិធីថតរូបកុមារ(Uploud)

3.5. កម្មវិធីសប្បាយនៅតាមភូមិ

3.6. រៀបចំកម្មវិធីសិក្សាបន្ថែមជាមួយក្លិបកុមារទាំងពីរដែលទើបសាងសង់រួច

3.7. ពង្រឹងពីការតាមដានការបង្រៀន និងរៀនតាមសាលារៀន និងការជួយចូលរួមថែរក្សា និងអនាម័យសាលារៀន

3.8. គណៈកម្មការទ្រទ្រង់សាលាថ្នាក់ឃុំ ធ្វើការជាមួយគកសកក្នុងការជួយដល់កុមារតាមសាលារៀនក្នុងការផ្សព្វផ្សាយពី PRS សិទ្ធិកុមារ សិទ្ធិស្ត្រី អំពើហឹង្សា គ្រោះថ្នាក់ពេលធ្វើចំណាកស្រុក។

3.9. ចងក្រងរបាយការណ៍PRSថ្នាក់ជាតិដើម្បីតស៊ូមតិ(MPC,CWDCC,CTO,COFAP,RFCD)

**លទ្ធផលទី៤៖CTOជាស្ថាប័នដែលមានគណនេយ្យភាព និងតម្លាភាពចំពោះម្ចាស់ជំនួយ និងអ្នកទទួលផល។**

4.1 ការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ(ខែវិច្ឆិការ)

4.2 ត្រួតពិនិត្យនិងឆ្លុះបញ្ចាំងការអនុវត្តសកម្មភាពប្រចាំត្រីមាស (comprehensive monitoring)

4.3 រៀបចំ និងត្រួតពិនិត្យផែនការឆ្នាំ ២០២០

4.4 . ចូលរួមសិក្ខាសាលាភាពជាដៃគូរប្រចាំឆ្នាំ

4.5 . ការចូលរួមនិងប្រជុំជាមួយបណ្តាញផ្សេងៗ AAC, NEP, WGPD, CHF, NGO forum and AAC-partnership

សៀមរាបថ្ងៃទី............ខែ.................... ឆ្នាំ២០១៩

រៀបចំរបាយការណ៍ដោយ

**នាយកប្រតិបត្តិ**

បានឃើញនិងពិនិត្យ

**ប្រធានក្រុមប្រឹក្សាភិបាល**

............................

.................................